# ព្រះរាជក្រឹត្យ

នស/រកត/០២១៦/១៨៤

## ស្តីពី

## ការកែសម្រួលមាត្រា៣ មាត្រា៤ និងមាត្រា២២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

# ត្រាស់បង្គាប់

**មាត្រាមួយ .-**

មាត្រា៣ មាត្រា៤ និងមាត្រា២២នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០៩/៤១៣ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈវិស្វករកម្ពុជា ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា៣ថ្មី .-**

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះវិស្វករខ្មែរនិងវិស្វករបរទេសដែលប្រកបវិជ្ជាជីវៈវិស្វកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ថ្មី .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងព្រះរាជក្រឹត្យនេះមាននិយមន័យដូចតទៅ៖

- **វិស្វករ** សំដៅដល់រូបវន្តបុគ្គលខ្មែរឬរូបវន្តបុគ្គលបរទេសដែលបានបញ្ចប់ការសិក្សាជំនាញវិស្វកម្ម ដោយជោគជ័យ នៅតាមគ្រឹះស្ថានឧត្តមសិក្សានៅព្រះរាជាណាចក្រកម្ពុជាឬនៅបរទេស ហើយមាន ការទទួលស្គាល់សញ្ញាបត្រស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា
- **វិស្វករចុះបញ្ជី** សំដៅដល់វិស្វករដែលបានចុះបញ្ជីនៅ **គ.វិ.ក**.
- **វិស្វករអាជីព** សំដៅដល់រូបវន្តបុគ្គលខ្មែរឬរូបវន្តបុគ្គលបរទេស ដែលបានចុះឈ្មោះទទួលស្គាល់ក្នុង បញ្ជីនៃ **គ.វិ.ក**. និងបានបំពេញលក្ខខណ្ឌស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណា-ចក្រកម្ពុជា
- **វិស្វករអាស៊ាន** សំដៅដល់រូបវន្តបុគ្គលដែលមានសញ្ជាតិ ក្នុងប្រទេសជាសមាជិកអាស៊ាននិងមាន លក្ខណសម្បត្តិគ្រប់គ្រាន់ ស្របតាមកិច្ចព្រមព្រៀងនៃការទទួលស្គាល់គ្នាទៅវិញទៅមកលើសេវាកម្ម វិស្វកម្មរបស់អាស៊ាន ក្រោមការត្រួតពិនិត្យនិងវាយតម្លៃរបស់គណៈកម្មាធិការចុះបញ្ជីវិស្វករអាស៊ាន
- **វិជ្ជាជីវៈវិស្វកម្ម** សំដៅដល់ការងារជំនាញខាងការសិក្សាគម្រោង ការអនុវត្ត និងលិខិតបទដ្ឋាន បច្ចេកទេសទាំងឡាយដែលទាក់ទងនឹងការងារវិស្វកម្ម។

**មាត្រា២២ថ្មី .-**

វិស្វករបរទេសដែលមានបំណងប្រកបវិជ្ជាជីវៈវិស្វកម្មនៅព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីនៅ **គ.វិ.ក**. និងត្រូវគោរពតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រាពីរ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី ..**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ២០១៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកត/០២១៦/១៨៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ហត្ថលេខា**
**សុខ អាន**

លេខ: ១៩៥ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**